**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**នាយកដ្ឋានផែនការនិងស្ថិតិ**

លេខ:.....៤៦៣...... នផ.

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ:** របាយការណ៍លទ្ធផលសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព នៃការអនុវត្តថវិកាតាមកម្មវិធីឆ្នាំ ២០១៦ និងការរៀបចំផែនការថវិកាកម្មវិធីឆ្នាំ២០១៧។

**ជូនភ្ជាប់:**-ឯកសារសិក្ខាសាលាចំនួន.........................................................០១ច្បាប់

-បញ្ជីវត្តមានអ្នកចូលរួមចំនួន.........................................................០១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថាកាលពីថ្ងៃទី១៤-១៥ ខែកក្កដា ឆ្នាំ២០១៦ នាយកដ្ឋានផែនការនិងស្ថិតិ បានរៀបចំសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃការអនុវត្តថវិកាតាមកម្មវិធីឆ្នាំ២០១៦ និងការរៀបចំផែនការថវិកាកម្មវិធីឆ្នាំ២០១៧ នៅសណ្ឋាគារ ហ្គោលឌិនស៊ុី ខេត្តព្រះសីហនុ ដោយមានការគាំទ្រថវិកាពីគម្រោងសហគមន៍អឺរ៉ុប(EU)។

សិក្ខាសាលានេះបានដំណើរការ និងប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម **តិត សេង** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសិក្ខាកាមចូលរួមជាមន្ត្រីរាជការចំនួន៥៣រូបដែលមកពីគ្រប់អង្គភាពថវិកានៅថ្នាក់កណ្តាល (ដូចមានបញ្ជីវត្តមានជូនភ្ជាប់)។

**គោលបំណងសំខាន់ៗ** នៃសិក្ខាសាលាគឺដើម្បី ÷ (១)ពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃការអនុវត្តថវិកាតាមកម្មវិធី២០១៦ និងរៀបចំផែនការថវិកាកម្មវិធី២០១៧-២០១៩ និង(២)ពង្រឹងសមត្ថភាពមន្ត្រីក្នុងការរៀបចំ និងអនុវត្តថវិកាកម្មវិធីឲ្យមានប្រសិទ្ធភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ចំពោះលទ្ធផលរបស់សិក្ខាសាលា ខ្ញុំសូមអនុញ្ញាតរាយការណ៍ជូនជាសង្ខេបដូចខាងក្រោម÷

**-លោកស្រី វុន្នី** ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ បានមានមតិស្វាគមន៍ជូនអង្គសិក្ខាសាលាដែលបានលើកឡើងអំពីការផ្លាស់ប្តូរនូវរបទថ្មីមួយនៃរបៀបរបបធ្វើការងារ ដែលអនុញ្ញាតឲ្យសាមីអង្គភាពនីមួយៗ បានបង្ហាញពីការអនុវត្តថវិកា ពីដំណើរការរៀបចំផែនការថវិកា ការលើកឡើងនូវបញ្ហាប្រឈម និងកង្វះខាតផ្សេងៗ ដើម្បីពិភាក្សារួមគ្នារកដំណោះស្រាយ ។

**-ឯកឧត្តម តិត សេង** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឡើងថ្លែងសុន្ទរកថា ដោយបានលើកឡើងនូវខ្លឹមសារគន្លឹះ សំខាន់ៗ ទាក់ទងនឹង÷

➢ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញទិសដៅជាយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-២០២០ ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហ៊ានៗ ពីការផ្តោតលើធាតុចូល និងមជ្ឈការទៅ

អាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។
No. 200, Preah Norodom Blvd, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh.
ទូរស័ព្ទ: (855) 23 720-527 or (855) 23 216-060
ទូរសារ: (855) 23 720-527 or (855) 23 216-060

រកប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការផ្អែកតាមទិសដៅនៃកម្មវិធីកំណែទម្រង់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាក្រសួងមួយក្នុងចំណោមក្រសួងដែលត្រូវបានដាក់ឱ្យអនុវត្ត ថវិកាកម្មវិធីពេញលេញ ដោយមានការវិភាជន៍ថវិកា និងការធ្វើប្រតិភូកម្មសិទ្ធិអំណាច ក្នុងការអនុវត្តចំណាយថវិកាដល់បណ្តាអង្គភាពថវិកាកម្មវិធីមួយចំនួនដែលបានបង្កើតឡើងនាពេលកន្លងមក។

- ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរៀបចំស្រប តាមខ្លឹមសារនៃសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧ និងបានគ្របដណ្តប់ថវិកា ទាំងអង្គភាពបច្ចេកទេសថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្តទាំង២៥។
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំផែនការថវិកា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកែសម្រួលនូវសមាសភាពក្រុមការងារចំនួន ០២ គឺ÷ (១)ក្រុមការងាររៀបចំថវិកា (២)ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួងដែលក្រុមទាំងពីរនេះដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការក្រសួង និងមានសមាសភាពចម្រុះពីអង្គភាពសំខាន់ៗ ពិសេសពីនាយកដ្ឋានផែនការនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ។

បទបង្ហាញរបស់អង្គភាពថវិកាចំនួន ០៥ គឺអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ស្តីពីលទ្ធផលនៃការអនុវត្តថវិកាតាមកម្មវិធីឆ្នាំ២០១៦ បញ្ហាប្រឈម និងសំណូមពរ។

- **កម្មវិធីទី១ ÷ បង្កើនផលិតភាព ពិពិធកម្មវូបនីយកម្មនិងពាណិជ្ជូបណីយកម្មកសិកម្ម**មាន០២អង្គភាពបានបង្ហាញនូវលទ្ធផលនៃការអនុវត្តថវិកាកម្មវិធីគិតត្រឹមត្រីមាសទី២។ (១) អគ្គនាយកដ្ឋានកសិកម្មគឺមានអនុកម្មវិធីចំនួន ១០ បានដាក់ចេញនូវសកម្មភាពចំនួន ៩៥ ដោយសម្រេចបានលទ្ធផល ២៨%និងប្រើប្រាស់ថវិកាអស់ចំនួន ៦ ៣៩៨ ២៤០ ០៥០រៀល ស្មើ៣៥% (២)អគ្គនាយកដ្ឋានកៅស៊ូ បានអនុវត្តអនុកម្មវិធីចំនួន ០៥ បានដាក់ចេញនូវសកម្មភាពចំនួន ១៧ ដោយសម្រេចបានលទ្ធផល ៣៣% និងប្រើប្រាស់ថវិកាអស់ចំនួន ១៤០ ២២៩ ៧២៩ រៀល ស្មើ៤០%។
- **កម្មវិធីទី២ ÷ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ**អនុវត្តដោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មានអនុកម្មវិធីចំនួន៩ បានដាក់ចេញនូវសកម្មភាពចំនួន ៣៥ ដោយសម្រេចបានលទ្ធផល ៤០% និងប្រើប្រាស់ថវិកាអស់ចំនួន ៤ ៩១៣ ០០០ ០០០រៀល ស្មើ៣៦%។
- **កម្មវិធីទី៣ ÷ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព** អនុវត្តដោយរដ្ឋបាលជលផល មានអនុកម្មវិធីចំនួន១១ បានដាក់ចេញនូវសកម្មភាពចំនួន៥០ ដោយសម្រេចបានលទ្ធផល៥៥% និងប្រើប្រាស់ថវិកាអស់ចំនួន១០ ៤៨៦ ០១៩ ០០០ រៀល ស្មើ៤៦%។
- **កម្មវិធីទី៤ ÷ ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាពៈ** អនុវត្តដោយរដ្ឋបាលព្រៃឈើ មានអនុកម្មវិធីចំនួន ០៨ បានដាក់ចេញនូវសកម្មភាពចំនួន ៥៨ ដោយសម្រេចបានលទ្ធផល ៤៧% និងប្រើប្រាស់ថវិកាអស់ចំនួន ៨ ៧៣៧ ៣០០ ០០០រៀល ស្មើ២២%។

ជារួមការអនុវត្តលើថវិកាកម្មវិធីក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៦ សម្រេចបានលទ្ធផលប្រមាណ ៤១% និង ប្រើប្រាស់ថវិកាអស់ ៣៥% ។

បន្ទាប់ពីបញ្ចប់ការធ្វើបទបង្ហាញដោយតំណាងអង្គភាពនីមួយៗ អង្គសិក្ខាសាលាបានពិភាក្សាពេញអង្គ ទៅលើលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី៦ខែដើមឆ្នាំ២០១៦ ក្នុងនោះអង្គសិក្ខាសាលាបានពិនិត្យលើ (ឈ្មោះសកម្មភាព ការកំណត់ឈ្មោះសូចនាករ និងចំនុចដៅជាដើម)បញ្ហាប្រឈម និងសំណូមពរ ដើម្បីរកនូវដំណោះស្រាយជារួមសម្រាប់ការអនុវត្តឲ្យមានភាពរលូន និងប្រកបដោយប្រសិទ្ធភាព ដូចមានចំនុចមួយចំនួនដូចតទៅ ÷

១.សមត្ថភាពមន្ត្រីលើការងាររៀបចំផែនការសកម្មភាព ថវិកា និងការតាមដាននិងវាយតម្លៃនៅមានកំរិត

២.នីតិវិធីនៃការចំណាយ និងការទូទាត់ថវិកា នៅមានភាពស្មុគស្មាញ និងសុង្គតភាព

៣.ការប្រែប្រួលនៃការគ្រប់គ្រងព្រៃឈើ

៤.គ្រោះរាំងស្ងួតប៉ះពាល់ដល់ដំណើរការពិសោធន៍ អភិរក្ស និងបន្សុទ្ធពូជបន្លែ រុក្ខជាតិលម្អ និងផ្លែឈើ

៥.ការផ្គត់ផ្គង់សម្ភារកសិកម្មតាមរយៈលទ្ធកម្មមិនបានទាន់ពេលវេលានៃរដូវកាលដាំដុះ

៦.ការផ្តល់ថវិកាតាមជុំនីមួយៗនៅមានភាពយឺតយ៉ាវ ។

**គណៈអធិបតី និងវាគ្មិន បានណែនាំដល់អង្គភាពថវិកាដូចតទៅ÷**

១.វគ្គបណ្តុះបណ្តាលលើការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ជាតម្រូវការចាំបាច់សម្រាប់មន្ត្រីថ្នាក់ក្រោមជាតិ និងត្រូវពង្រឹងបន្ថែមដល់មន្ត្រីដែលទទួលបន្ទុកការងារនេះ ។

២.បានទទួលព័ត៌មាន និងផ្លាស់ប្តូរបទពិសោធន៍លើការអនុវត្តថវិកាតាមកម្មវិធី២០១៦ ។

៣.បានធ្វើការណែនាំ ÷

ក/ស្នើឲ្យមានការសន្សំសំចៃលើការចាយវាយថវិកា ពិសេសកុំឲ្យសកម្មភាពមួយប្រើប្រាស់ថវិកា ជាន់គ្នាមកពីប្រភពផ្សេងៗ (ថវិការដ្ឋផង ថវិកាជំនួយដៃគូផង) បើករណីកើតមានឡើង អ្នកអនុវត្តត្រូវទទួលខុសត្រូវនៅពេលគេធ្វើសវនកម្មរកឃើញ។

ខ/អង្គភាពទាំងអស់ដែលទទួលបានថវិកាកម្មវិធី ត្រូវបង្ហាញពីលទ្ធផលអនុវត្តឲ្យបានច្បាស់លាស់ និងសមស្របតាមទំហំថវិកា ឧទាហរណ៍ សកម្មភាពដាំឈើរបស់រដ្ឋបាលព្រៃឈើ តាមឆ្នាំនីមួយៗត្រូវបង្ហាញពីទំហំផ្ទៃដីដាំដុះ ទីតាំងដាំដុះ ភាពដុះរបស់កូនឈើដាំ និងផលឈើបានពីការដាំ...។ល។

**អនុសាសន៍ និងសំណូមពរនៃអង្គសិក្ខាសាលា÷**

ជាសរុប អង្គសិក្ខាសាលាបានសំណូមពរនូវចំនុចមួយចំនួនដូចខាងក្រោម÷

១.ស្នើសុំផ្តល់ថវិកាបុរេប្រទានចំនួន៤ជុំ ហើយជុំនីមួយៗគឺស្នើសុំផ្តល់ ១០០%តែម្តង នៃថវិកាសរុបតាមជុំ។

២.ស្នើសុំកាត់បន្ថយបែបបទនីតិវិធី និងរយៈពេលទូទាត់ថវិកាក្រៅប្រទេសឲ្យបានខ្លីជាងបច្ចុប្បន្ន។

៣.ស្នើសុំបើកមានវគ្គបណ្តុះបណ្តាលបន្ថែមស្តីពីការរៀបចំផែនការការទូទាត់ថវិកា ការតាមដាននិងវាយតម្លៃដល់មន្ត្រីជំនាញដែលទទួលបន្ទុកការងារនេះ ។

៤.ការធ្វើលទ្ធកម្មមានការអូសបន្លាយពេលយូរ ស្នើមានវិធានការកាត់បន្ថយនីតិវិធី និងពេលវេលាសម្រាប់ករណីពិសេសដូចជាសកម្មភាពដែលត្រូវការបន្ទាន់និងចាំបាច់ ជាក់ស្តែងវ៉ាក់សាំងសត្វជាដើម...។

៥.ការកសាងចង្កោមភាពត្រូវពិនិត្យលើតួនាទីភារកិច្ចរបស់សាមីអង្គភាព។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម**ឯកឧត្តមរដ្ឋមន្ត្រី**មេត្តាជ្រាបជាសេចក្តីរាយការណ៍ និងមានវិធានការសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៦

**ប្រធាន**

**នាយកដ្ឋានផែនការនិងស្ថិតិ**

**ស្រី ចុន្នី**

ចម្លងជូន÷

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋានផែនការនិងស្ថិតិ
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋានផែនការនិងស្ថិតិ
- ឯកសារ កាលប្បវត្តិ